ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
ប្រ.ក/លេខ ០៥.០៣៦/១៣ គ.ជ.ប.អគ្គ.ពស

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៣

# មន្ត្រី គ.ជ.ប ជួបជាមួយប្រតិភូបរទេសស្វែងយល់ការបោះឆ្នោតនៅកម្ពុជា

កាលពីថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៣ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត(គ.ជ.ប) បានចាត់តាំងមន្ត្រី ៣រូប ជាតំណាងជួបជាមួយប្រតិភូបរទេសចំនួន ៦ប្រទេស មកស្វែងយល់លើការប្រើប្រាស់ប្រព័ន្ធ IVR (Interactive Voice Respone system) ដែលកម្ពុជាប្រើជាលើកដំបូងសម្រាប់ផ្តល់សេវាព័ត៌មានបោះឆ្នោតដល់អ្នកបោះឆ្នោត ។

លោក ខន កែវមនោ អនុប្រធានទទួលបន្ទុកផ្នែកព័ត៌មានសាធារណៈ បានមានប្រសាសន៍ថា IVR គឺជាប្រព័ន្ធឆ្លើយតបជាសំឡេងដែលចែកចាយព័ត៌មានបោះឆ្នោតដល់អ្នកបោះឆ្នោត តាមរយៈទូរស័ព្ទដៃរបស់ពួកគេ ហើយអ្នកប្រើប្រាស់សេវាព័ត៌មាន ឬក៏អ្នកស្តាប់ព័ត៌មាននេះ ពុំមានអស់ទឹកប្រាក់ទេ ។ លោកបន្តថាសម្រាប់ការបោះឆ្នោតជាតិឆ្នាំ២០១៣ ជាលើកដំបូង ហើយដែល គ.ជ.ប បានសហការជាមួយនឹងវិទ្យាស្ថានបើកទូលាយ និងមូលនិធិអន្តរជាតិ សម្រាប់ប្រព័ន្ធបោះឆ្នោត (IFES) ដើម្បីបង្កើតប្រព័ន្ធឆ្លើយតបជាសំឡេងក្នុងគោលបំណងលើកកំពស់ការយល់ដឹង និងទទួលបានព័ត៌មានតាមរយៈមធ្យោបាយមួយយ៉ាងងាយស្រួល ។

លោកបានបញ្ជាក់ទៀតថា ដោយចង់ស្វែងយល់ពី IVR ទើបប្រតិភូបរទេសចំនួន ៦ប្រទេស រួមមាន ៖ ប្រទេសនីហ្សេរីយ៉ា សេរ៉ាឡេអូន កេនយ៉ា ហ្សេនេកាល់ នេប៉ាល់ និងតំណាងអានហ្វ្រេល មានមូលដ្ឋាននៅទីក្រុងបាងកក ដែលប្រតិភូទាំងអស់ដឹកនាំដោយ COMFREL បានមកស្វែងយល់ពីការងារនេះ ៕

ទំនាក់ទំនងព័ត៌មាន៖ ០២៣ ២១៤ ៣៧៤ / ០១២ ៨៥៥ ០១៨ ; E-mail: necinfo@forum.org.kh; www.necelect.org.kh